# បទវិភាគច្បាប់សង្ខេប នៃសេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន[1]

## សេចក្តីផ្តើម

"សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន" នឹងផ្តល់អំណាចយ៉ាងទូលាយ និងគ្មានដែនកំណត់ ដល់រាជរដ្ឋាភិបាលកម្ពុជា ដោយមិនមានយន្តការត្រួតពិនិត្យណាមួយនោះទេ ។ ពាក្យពេចន៍ដែលមានន័យទូលាយ និងមិនសូវច្បាស់លាស់ នៅក្នុងសេចក្តីព្រាងច្បាប់នេះ អាចត្រូវបានគេបកស្រាយបានយ៉ាងទូលំទូលាយ ដើម្បីធ្វើឱ្យការដាក់ប្រទេសជាតិក្នុងភាពអាសន្ន ស្របច្បាប់ស្ទើរតែនៅគ្រប់ស្ថានភាពទាំងអស់ ។ ដោយមិនមានកំណត់ពេលវេលាបញ្ចប់ច្បាស់លាស់ ការប្រកាសដាក់ប្រទេសក្នុងគ្រាអាសន្ន អាចនឹងត្រូវបានធ្វើឡើងក្នុងរយៈពេលយូរអង្វែង ។ សិទ្ធិសេរីភាពជាច្រើន អាចនឹងត្រូវបានហាមឃាត់ ឬរឹតត្បិត ដោយមិនកំណត់ថេរវេលា ។ សិទ្ធិសេរីភាពដែលប៉ះពាល់ រួមមានសិទ្ធិក្នុងការធ្វើដំណើរ ជួបជុំឬប្រមូលផ្តុំ ការធ្វើសកម្មភាពការងារ ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការបញ្ចេញមតិ ។

រាជរដ្ឋាភិបាល នឹងទទួលបានអំណាចក្នុងការតាមដានត្រួតពិនិត្យគ្មានដែនកំណត់ ទៅលើទំនាក់ទំនងរបស់ពលរដ្ឋទាំងអស់ និងការហាមឃាត់ការចែកចាយព័ត៌មានមួយ ឬច្រើន ដែលអាជ្ញាធរសម្រេចមិនឱ្យផ្សព្វផ្សាយ ។ អាជ្ញាធរ អាចប្រើប្រាស់សេចក្តីព្រាងច្បាប់នេះ ដើម្បីប្រើប្រាស់កងទ័ពគ្រប់គ្រងលើស្ថាប័នស៊ីវិលមួយឬច្រើន ក្នុងគោលបំណងរៀបចំ និង គ្រប់គ្រងប្រទេស ។ ចុងក្រោយ ទណ្ឌកម្មព្រហ្មទណ្ឌដែលមិនអាចកំណត់ទុកជាមុន និងមានលក្ខណៈមិនសមាមាត្រនឹងអំពើល្មើស អាចនឹងត្រូវបានប្រើប្រាស់ទៅលើប្រជាពលរដ្ឋ តាមរយៈការចោទពីបទល្មើសជាច្រើន ដែលមាននិយមន័យមិនច្បាស់លាស់ ។ នីតិបុគ្គល ដូចជាអង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ឬសហជីពអាចនឹងប្រឈមមុខនឹងទោសធ្ងន់ធ្ងរ ដូចជាការរំលាយចោល ប្រសិនបើស្ថាប័ននោះរំលោភនឹងច្បាប់នេះ ។ ដូចនេះ ការព្រួយបារម្ភថា សេចក្តីព្រាងច្បាប់នេះ នៅពេលដែលត្រូវបានអនុម័ត នឹងត្រូវបានប្រើប្រាស់ដើម្បីបំបិទសិទ្ធិសេរីភាពរបស់ពលរដ្ឋ គឺជាការសមហេតុផល ។

---

[1] បទវិភាគផ្នែកច្បាប់នេះ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើសេចក្តីព្រាងច្បាប់ ដែលត្រូវបានបែកធ្លាយជាសាធារណៈ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២០ ។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានអនុម័តដោយគណកម្មាធិការអចិន្ត្រៃយ៍នៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសម្តេចនាយករដ្ឋមន្ត្រីជាប្រធាន ។

## ជំពូកទី ១៖ បទបញ្ញត្តិទូទៅ

មាត្រា ១ និង មាត្រា ២ ចែងអំពីគោលបំណង និងវិសាលភាពនៃការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ។ សិទ្ធិរបស់រាជរដ្ឋាភិបាល ក្នុងការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន គឺមានចែងក្នុងមាត្រា ២២ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលតម្រូវឱ្យមានការព្រមព្រៀងជារួមមួយរវាងនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភានិងព្រឹទ្ធសភា និងព្រះមហាក្សត្រ ។ ព្រះមហាក្សត្រ បន្ទាប់មកទ្រង់នឹងប្រកាសដាក់ប្រទេសនៅក្នុងភាពអាសន្ន ។

យោងតាមមាត្រា ៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR) ដែលកម្ពុជាជាប្រទេសហត្ថលេខី កំណត់ថា រដ្ឋសមាជិកអាចដាក់ប្រទេសជាតិក្នុងភាពអាសន្ន ដោយអាចលើកលែងពីការទទួលខុសត្រូវមួយចំនួនទៅតាមកតិកាសញ្ញានេះ ។ ប៉ុន្តែមាត្រាដដែល ក៏បានចែងថា សកម្មភាពរបស់រដ្ឋជាសមាជិក ចាំបាច់ត្រូវតែមានភាពសមាមាត្រ នៅពេលដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន និងមិនអាចរំលោភនឹងកាតព្វកិច្ចផ្សេងទៀតរបស់រដ្ឋសមាជិកក្រោមច្បាប់អន្តរជាតិនោះទេ ។ សកម្មភាពមួយចំនួន ដែលរដ្ឋជាសមាជិកមិនអាចធ្វើបាន ដូចជា៖

- រើសអើសទៅលើបុគ្គលណាម្នាក់ដោយសារជាតិពន្ធុ ពណ៌សម្បុរ ភេទ ភាសា សាសនា ឬដើមកំណើតជាតិសាសន៍[2]
- ដកហូតជីវិតបុគ្គលណាម្នាក់ដោយមិនត្រឹមត្រូវ[3]
- ធ្វើទារុណកម្ម និងទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប លើបុគ្គលណាម្នាក់[4]
- ដាក់បុគ្គលណាម្នាក់ជាទាសករ[5] ឬការងារដោយបង្ខំ[6]
- ដាក់បុគ្គលណាម្នាក់ក្នុងពន្ធនាគារ ដោយមូលហេតុបុគ្គលនោះមិនមានសមត្ថភាពបំពេញតាមកាតព្វកិច្ចដែលមានក្នុងកិច្ចសន្យា[7]
- រកឃើញថាបុគ្គលណាម្នាក់មានពិរុទ្ធលើបទល្មើស ដែលមិនមានចែងថាជាបទល្មើសព្រហ្មទណ្ឌក្នុងច្បាប់ជាតិ និងអន្តរជាតិ នៅពេលដែលអំពើនោះបានកើតឡើង[8]
- ដកហូតសិទ្ធិបុគ្គលណាម្នាក់ក្នុងការឱ្យគេទទួលស្គាល់បុគ្គលិកលក្ខណៈគតិយុត្តិរបស់ខ្លួននៅគ្រប់ទីកន្លែង[9]
- រឹតត្បិតសិទ្ធិសេរីភាពបុគ្គល ទៅលើសេរីភាពនៃគំនិត សតិសម្បជញ្ញៈ និងសាសនា ។ សិទ្ធិនេះ រួមតាំងសិទ្ធិក្នុងការកាន់ ឬគោរពសាសនា ឬជំនឿណាមួយតាមការជ្រើសរើសរបស់ខ្លួន និងសេរីភាពក្នុងការសម្តែង

---

[2] មាត្រា ៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

[3] មាត្រា ៦(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

[4] មាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

[5] មាត្រា ៨(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

[6] មាត្រា ៨(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

[7] មាត្រា ១១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

[8] មាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

[9] មាត្រា ១៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

សាសនា ឬជំនឿរបស់ខ្លួនដោយម្នាក់ៗ ឬដោយរួមជាមួយអ្នកដទៃ និងជាសាធារណៈ ឬជាឯកជនតាមការគោរពបូជា ការប្រតិបត្តិតាម ការអនុវត្តន៍ និងការបង្ហាត់បង្រៀន ។[10]

## ជំពូកទី ២៖ បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

ការប្រើប្រាស់ពាក្យ "គ្រោះថ្នាក់" ដែលមិនមាននិយមន័យច្បាស់លាស់ ក្នុងមាត្រា ៣ នៃសេចក្តីព្រាងច្បាប់នេះ គឺជាការព្រួយបារម្ភមួយ ។ ទោះបីជាមាត្រានេះ ចែងស្របនឹងមាត្រា ២២ នៃរដ្ឋធម្មនុញ្ញកម្ពុជាក៏ដោយ ក៏ពាក្យថា "គ្រោះថ្នាក់" នៅតែត្រូវបានប្រើប្រាស់ដូចក្នុងមាត្រា ២២ នៃរដ្ឋធម្មនុញ្ញ ដោយមិនមានការផ្តល់និយមន័យច្បាស់លាស់បន្ថែមនោះទេ ។ ការណ៍នេះ អាចនឹងធ្វើឱ្យមានការបកស្រាយទូលំទូលាយ ដែលធ្វើឱ្យការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន អាចនឹងត្រូវបានធ្វើឡើងស្ទើរគ្រប់ស្ថានភាពទាំងអស់ ដែលអាជ្ញាធរគិតថាប្រទេសមាន "គ្រោះថ្នាក់" ។

មាត្រា ៣ នៃសេចក្តីព្រាងច្បាប់នេះ ផ្តល់សិទ្ធិដល់ព្រះមហាក្សត្រក្នុងការប្រកាសប្រទានដំណឹងដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ក្រោយពីបានការឯកភាពជារួមពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា ។ ការប្រកាសដាក់ប្រទេសស្ថិតក្នុងភាពអាសន្ន ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

នៅក្នុងករណីដែលព្រះមហាក្សត្រ មិនអាចបំពេញព្រះរាជភារៈជាព្រះប្រមុខរដ្ឋបាន មាត្រា ១១ នៃរដ្ឋធម្មនុញ្ញផ្តល់សិទ្ធិដល់ប្រធានព្រឹទ្ធសភា "បំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ"។[11] មាត្រា ២៨ នៃរដ្ឋធម្មនុញ្ញ បានចែងបន្ថែមថា ព្រះមហាក្សត្រ "មានសិទ្ធិផ្ទេរអំណាចឡាយព្រហស្តលេខានៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យ ទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ"[12] ដែលប្រមុខរដ្ឋស្តីទីនៅក្នុងស្ថានភាពនេះ អាចជាប្រធានព្រឹទ្ធសភា ។

ការផ្ទេរភារកិច្ច និងទំនាក់ទំនង ដែលមានចែងក្នុងមាត្រាខាងលើទាំងនេះ បានបង្ហាញថា នៅក្នុងស្ថានភាពនៃការប្រកាសដាក់ប្រទេសជាតិក្នុងភាពអាសន្ន ប្រសិនបើព្រះមហាក្សត្រ មិនអាចបំពេញព្រះរាជភារៈជាធម្មតាបានដោយសារមូលហេតុដូចជា "ជំងឺធ្ងន់ធ្ងរ"[13] ឧត្តមមន្ត្រីទាំងបីរូប ដែលមានប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នឹងទទួលបានសិទ្ធិសម្រេចឱ្យមានការព្រមព្រៀងជារួម ដើម្បីប្រកាសដាក់ប្រទេសស្ថិតក្នុងភាពអាសន្ន ។

ការព្រមព្រៀងជារួមរវាងព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា គឺជាជំហានទីមួយ ។ ជំហានបន្ទាប់ គឺ "រដ្ឋជាសមាជិក" ត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិនូវ "បទបញ្ញត្តិទាំងឡាយណា និងមូលហេតុ ដែលរដ្ឋសមាជិកនោះបានធ្វើបដិបញ្ញត្តិ (ចែងច្បាប់ផ្ទុយនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ)"[14] ។ ដូចនេះ រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ

[10] មាត្រា ១៨(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

[11] មាត្រា ១១ នៃរដ្ឋធម្មនុញ្ញកម្ពុជា

[12] មាត្រា ២៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា

[13] មាត្រា ១១ នៃរដ្ឋធម្មនុញ្ញកម្ពុជា

[14] មាត្រា ៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

ដោយត្រូវបង្ហាញនូវបញ្ញត្តិអន្តរជាតិទាំងឡាយណា ព្រមទាំងមូលហេតុ ដែលអាជ្ញាធរកម្ពុជា បានសម្រេចមិនអនុវត្តតាម នៅពេលដែលប្រទេសជាតិក្នុងស្ថានភាពអាសន្ន ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ក្នុងមាត្រា ៣ នៃសេចក្តីព្រាងច្បាប់នេះ បានចែងថា ការប្រកាសដាក់ប្រទេសក្នុងស្ថានភាពអាសន្ន អាចធ្វើឡើងដោយមានថេរវេលាកំណត់ ឬមិនមានថេរវេលាកំណត់ ។ ការកំណត់បែបនេះ នឹងអាចប្រឈមនឹងការដាក់ប្រទេសក្នុងស្ថានភាពអាសន្នរយៈពេលយូរអង្វែង ។ ការប្រកាសដាក់ប្រទេសក្នុងភាពអាសន្នទាំង "មានថេរវេលាកំណត់ និងមិនមានថេរវេលាកំណត់" នឹងត្រូវបញ្ចប់ដោយព្រះរាជក្រឹត្យ "នៅពេលសភាពការណ៍អនុញ្ញាត" អាចនឹងបន្តរហូតដោយគ្មានកំណត់ពេល ។ មាត្រា ៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ តម្រូវឱ្យការដាក់ប្រទេសក្នុងស្ថានភាពអាសន្ន មានភាពសមាមាត្រ ។ រដ្ឋជាសមាជិក អាចចាត់វិធានការចែងផ្ទុយនឹងកាតព្វកិច្ចក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ "ក្នុងកម្រិតដែលស្ថានភាពតម្រូវតែប៉ុណ្ណោះ"។ ការដាក់ប្រទេសស្ថិតក្នុងភាពអាសន្ន មិនអាចត្រូវបានធ្វើឡើងយូរពេកនោះទេ ដែលធ្វើឱ្យច្បាប់ដាក់ប្រទេសស្ថិតក្នុងភាពអាសន្នអាចក្លាយជា ផ្នែកមួយស្ទើរតែជាអចិន្ត្រៃយ៍ ឬជាអចិន្ត្រៃយ៍ នៃប្រព័ន្ធច្បាប់ផ្ទៃក្នុងរបស់ប្រទេស ។

មាត្រា ៤ នៃសេចក្តីព្រាងច្បាប់នេះ ចែងនូវនិយមន័យយ៉ាងស្រពិចស្រពិលនៃលក្ខខណ្ឌមួយចំនួននៃការដែលអាចដាក់ប្រទេសស្ថិតក្នុងភាពអាសន្នបាន ដូចជា "ភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខជាតិនិងសណ្តាប់ធ្នាប់សាធារណៈ" ។ ដោយមិនមានសេចក្តីណែនាំ ឬដែនកំណត់ជាក់លាក់នៃលក្ខខណ្ឌនេះ មាត្រានេះ អាចត្រូវបានគេបកស្រាយយ៉ាងទូលំទូលាយ ដើម្បីឱ្យអាជ្ញាធរអាចដាក់ប្រទេសក្នុងស្ថានភាពអាសន្ន ដោយស្របច្បាប់ "នៅពេលណា" ដែលសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ រងការគម្រាមកំហែង ។ បូករួមទាំងមាត្រា ១ ដល់ មាត្រានេះ ច្បាប់នេះ នឹងអនុញ្ញាតឱ្យអាជ្ញាធរបន្តដាក់ប្រទេសស្ថិតក្នុងភាពអាសន្ន ដោយផ្អែកលើការប៉ះពាល់ដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ដោយមិនមានថេរវេលាកំណត់ ។

## ជំពូកទី ៣៖ ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

មាត្រា ៥ នៃសេចក្តីព្រាងច្បាប់នេះ ចែងអំពីវិធានការនានានៅពេលដាក់ប្រទេសជាតិក្នុងភាពអាសន្ន ដោយហាមឃាត់ និងរឹតត្បិតសិទ្ធិសេរីភាពមួយចំនួនរបស់ពលរដ្ឋដូចជា ៖

- *សេរីភាពក្នុងការធ្វើដំណើររបស់ពលរដ្ឋ ៖* មាត្រានេះ មិនមានការកំណត់ថេរវេលានៃការហាមឃាត់ ឬរឹតត្បិតនោះទេ ។ មាត្រា ៤០ រដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា ១២(១) នៃកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ធានានូវសេរីភាពនេះ ។ ការរឹតត្បិតទៅលើសិទ្ធិសេរីភាពនេះ អាចធ្វើទៅបាន លុះត្រាតែ "មានចែងក្នុងច្បាប់" និង "ចាំបាច់ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ" [15]។ ការរឹតត្បិតណាមួយទៅលើសេរីភាពនេះ គួរតែត្រូវបានធ្វើឡើងតែក្នុងស្ថានភាពបណ្តោះអាសន្ន និងដោយប្រើប្រាស់មធ្យោបាយរឹតត្បិតដែលមានលក្ខណៈតឹងតែងតិចតួចបំផុត ក្នុងការសម្រេចនូវគោលបំណងរបស់អាជ្ញាធរ ក្នុងគ្រោះអាសន្ន ។

---

[15] មាត្រា ១២(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ

- *សេរីភាពក្នុងការជួបជុំ ឬប្រមូលផ្តុំមនុស្ស៖* មាត្រា ៣៧ មាត្រា ៤១ និង មាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ២១ និង ២២(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ធានានូវសិទ្ធិសេរីភាពនេះ ។ អំឡុងពេលមានគ្រោះអាសន្នសុខភាពសាធារណៈ ការរឹតត្បិតជាបណ្តោះអាសន្នលើការជួបជុំដែលមានមនុស្សច្រើននៅក្បែរគ្នា គឺសមហេតុផល ។ ក៏ប៉ុន្តែ ការពង្រីកនូវវិសាលភាពអនុវត្តរបស់អាជ្ញាធរ ដោយហាមឃាត់ ឬរឹតត្បិត "សិទ្ធិរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល" គឺជាការព្រួយបារម្ភ និងមិនចាំបាច់ ។ ការរឹតត្បិតសិទ្ធិរបស់ពលរដ្ឋ ក្នុងការចូលរួម ឬចាកចេញ ដោយស្ម័គ្រចិត្ត ក្នុងក្រុមមនុស្សណាមួយ ដើម្បីគោលបំណងរួមស្របច្បាប់មួយ គឺជាការអនុវត្តច្បាប់នេះជ្រុលហួសហេតុ ។
- *សេរីភាពក្នុងការធ្វើការងារ ឬប្រកបមុខរបរ៖* យោងតាមមាត្រានេះ អាជ្ញាធរមានសិទ្ធិកំណត់ថាការងារ ឬមុខរបរមួយចំនួនជាក់លាក់ ជាអំពើខុសច្បាប់ ។ គ្មានការបញ្ជាក់ណាមួយ ត្រូវបានកំណត់នៅក្នុងមាត្រានេះ អំពីរបៀប និងមូលហេតុ ដែលការងារ ឬមុខរបរទាំងនោះ ត្រូវបានកំណត់ថាខុសច្បាប់ នោះទេ ។ នៅក្នុងអំឡុងពេលគ្រោះអាសន្នសុខភាពសាធារណៈ ការរឹតត្បិតជាបណ្តោះអាសន្នមួយចំនួន ទៅលើសកម្មភាពការងារមិនចាំបាច់មួយចំនួន អាចជាវិធានការសមហេតុផល ដើម្បីការពារពីការរីករាលដាលនៃជំងឺ ។ ក៏ប៉ុន្តែ ការហាមឃាត់ការប្រកបមុខរបរ ឬធ្វើការងារ គឺមិនស្របទៅនឹងច្បាប់ជាតិនោះទេ ជាពិសេសមាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញកម្ពុជា ។ សេចក្តីព្រាងច្បាប់នេះ មិនបានចែងពន្យល់ថាហេតុអ្វីការហាមឃាត់ការប្រកបមុខរបរ ឬធ្វើការងារ មានភាពចាំបាច់ នៅក្នុងពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ។
- *ហាមឃាត់ ឬរឹតត្បិតមិនឱ្យបុគ្គលចេញពីលំនៅឋាន ឬទីសំណាក់ណាមួយ, ការដាក់ចេញវិធានការចត្តាឡីស័ក ឬការដាក់ឱ្យនៅដោយឡែកក្នុងករណីគ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈបណ្តាលពីការឆ្លងរាលដាលនៃជំងឺ និងការដាក់ចេញវិធានការទាក់ទងនឹងកំណែន និងជម្លៀសពលរដ្ឋ ដើម្បីឆ្លើយតបចំពោះភាពអាសន្ន៖* វិធានការទាំងនេះ គួរតែត្រូវបានធ្វើឡើងឱ្យសមាមាត្រ និងក្នុងស្ថានភាពបណ្តោះអាសន្ន ។ ការរឹតត្បិតណាមួយទៅលើសេរីភាពទាំងនេះ គួរតែត្រូវបានធ្វើឡើងតែក្នុងស្ថានភាពបណ្តោះអាសន្ន និងដោយប្រើប្រាស់មធ្យោបាយរឹតត្បិតដែលមានលក្ខណៈតឹងតែងតិចតួចបំផុត ក្នុងការសម្រេចនូវគោលបំណងរបស់អាជ្ញាធរ ដោះស្រាយបញ្ហាគ្រោះអាសន្ននៃសុខភាពសាធារណៈ ។ វិធានការទាំងនេះ ក៏គួរតែត្រូវបានធ្វើឡើងក្នុងថេរវេលាខ្លីបំផុតនៅពេលដែលស្ថានភាពអាសន្នតម្រូវ ។
- *ការដាក់ចេញវិធានការទាក់ទងនឹងកំណែន ដកហូត គ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិ និងសេវា ដែលមានភាពចាំបាច់ដើម្បីឆ្លើយតបចំពោះភាពអាសន្ន ៖* ការដកហូតទ្រព្យសម្បត្តិដែលធ្វើឡើងដោយអាជ្ញាធរ និងការផ្តល់សំណងឱ្យបានយុត្តិធម៌ គួរតែត្រូវបានកំណត់ឱ្យបានច្បាស់លាស់ នៅក្នុងមាត្រានេះ ។ មាត្រា ១៧ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ធានាសិទ្ធិសេរីភាពខាងលើនេះ ហើយមាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញកម្ពុជា បានចែងបន្ថែមថា "ការដកហូតនៃសិទ្ធិកម្មសិទ្ធិពីជនណាម្នាក់ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌" ។ ដូចនេះ មាត្រា ៥ នៃសេចក្តីព្រាងច្បាប់នេះ គួរកំណត់ឱ្យបានច្បាស់លាស់ថាតើទ្រព្យសម្បត្តិអ្វីខ្លះ ដែល "ចាំបាច់" ក្នុងការដកហូត ពាក់ព័ន្ធនឹងការដាក់ប្រទេសស្ថិតក្នុងភាពអាសន្ន ។ អាជ្ញាធរ ក៏គួរតែផ្តល់នូវសំណងជាមុន "ឱ្យបានសមរម្យ និងយុត្តិធម៌" ស្របតាមរដ្ឋធម្មនុញ្ញ មុនពេលដកហូត ។

- *ការដាក់ចេញវិធានការទាក់ទងនឹងការកំណត់ថ្លៃទំនិញ និងសេវា ដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបចំពោះភាពអាសន្ន និង ការដាក់ចេញវិធានការទាក់ទងនឹងការបិទទីតាំងសាធារណៈ ឬឯកជនណាមួយ ដែលមានភាពចាំបាច់ដើម្បីឆ្លើយតបចំពោះភាពអាសន្ន៖* ការបិទទីតាំងសាធារណៈមួយចំនួន គួរតែត្រូវបានធ្វើឡើយ ដោយសមាមាត្រ និងជាបណ្តោះអាសន្ន ។ ការបិទទីតាំងទាំងនេះ គួរតែត្រូវបានធ្វើឡើង ក្នុងរយៈពេលខ្លីមួយ ដែលស្ថានភាពអាសន្នតម្រូវ ។ ទីតាំងសាធារណៈ មានសារៈសំខាន់សម្រាប់សេរីភាពក្នុងការជួបជុំ និងប្រមូលផ្តុំរបស់ពលរដ្ឋ ។ ដូចនេះ ទីតាំងទាំងនេះ គួរតែអាចប្រើប្រាស់វិញបានដោយពលរដ្ឋ កាន់តែឆាប់កាន់តែល្អ ។
- *ការដាក់ចេញនូវវិធានការឃ្លាំមើល និងតាមដានតាមគ្រប់មធ្យោបាយ ដើម្បីទទួលបានព័ត៌មានតាមរយៈប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍គ្រប់រូបភាព ក្នុងគោលបំណងឆ្លើយតបចំពោះភាពអាសន្ន ៖* លក្ខខណ្ឌនេះផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរ ក្នុងការត្រួតពិនិត្យតាមដានដោយគ្មានដែនកំណត់ និងគ្មានយន្តការណាមួយត្រួតពិនិត្យនោះទេ ។ មាត្រា ៤០ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៧(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ធានានូវសិទ្ធិឯកជនភាពរបស់ពលរដ្ឋគ្រប់រូប តាមគ្រប់មធ្យោបាយទូរគមនាគមន៍ ។ លក្ខខណ្ឌនៃសេចក្តីព្រាងច្បាប់នេះ មិនបានកំណត់ឱ្យបានច្បាស់លាស់ ថាតើមាត្រានេះ អនុវត្តទៅលើប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍សាធារណៈ ឬក៏ឯកជន ។ ការត្រួតពិនិត្យចាប់ពិរុទ្ធនេះ គឺជាការរំលោភច្បាប់ជាតិ និងអន្តរជាតិយ៉ាងធ្ងន់ធ្ងរ ។
- *ការហាមឃាត់ ឬការកម្រិតការចែកចាយ ឬការផ្សព្វផ្សាយព័ត៌មានដែលអាចបង្កឱ្យមានការភ័យខ្លាចដល់សាធារណជន ឬចលាចល ឬដែលនាំឱ្យខូចខាតដល់សន្តិសុខជាតិ ឬធ្វើឱ្យមានការភាន់ច្រឡំអំពីស្ថានភាពនៃភាពអាសន្ន៖* លក្ខខណ្ឌនេះ បានចែងយ៉ាងទូលាយ និងមិនច្បាស់លាស់ ។ នៅពេលប្រទេសមានភាពអាសន្ន លក្ខខណ្ឌនេះ អាចឱ្យអាជ្ញាធរមានសិទ្ធិគ្រប់គ្រង និងបិទគ្រប់ស្ថាប័នផ្សព្វផ្សាយព័ត៌មានទាំងអស់ រួមទាំងស្ថាប័នព័ត៌មានឯករាជ្យ ឬបណ្តាញសង្គម ។ ប្រជាពលរដ្ឋ អាចត្រូវបានអាជ្ញាធរចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ប្រសិនបើអ្នកទាំងនោះ ចែកចាយយោបល់ ដែលអាជ្ញាធរយល់ថា "ប៉ះពាល់ជាអវិជ្ជមានដល់សន្តិសុខជាតិ" ឬ "បណ្តាលឱ្យមានការភាន់ច្រឡំ" ។ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ទទួលបានព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មាន ត្រូវបានធានាដោយមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៩(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ។ លក្ខខណ្ឌដែលកំណត់មិនច្បាស់លាស់ និងមិនមាននិយមន័យជាក់លាក់ ក្នុងការហាមឃាត់ ឬរឹតត្បិត "ការចែកចាយព័ត៌មាន" ដែល "អាចបង្កឱ្យមានការភ័យខ្លាចដល់សាធារណជន" គឺផ្ទុយនឹងកាតព្វកិច្ចរបស់កម្ពុជា តាមច្បាប់ជាតិ និងអន្តរជាតិនោះទេ ។
- *ការដាក់ចេញវិធានការដទៃទៀតដែលសមស្រប និងចាំបាច់ ដើម្បីឆ្លើយតបចំពោះភាពអាសន្ន៖* លក្ខខណ្ឌនេះ ផ្តល់អំណាចដល់អាជ្ញាធរដោយគ្មានដែនកំណត់ និងអាចអនុវត្តបានគ្រប់ស្ថានភាពទាំងអស់ ។ លទ្ធភាពក្នុងការ "ដាក់ចេញវិធានការដទៃទៀត" នៅពេលណាដែលអាជ្ញាធរយល់ថា "សមស្រប និងចាំបាច់" អាចនឹងបង្កើតឱ្យមានភាពមិនច្បាស់លាស់ និងអនុញ្ញាតឱ្យអាជ្ញាធរអនុវត្តនូវវិធានការតឹងរ៉ឹងបន្ថែមថ្មីៗ ឬទោសទណ្ឌថ្មីៗ តាមចិត្តរបស់អាជ្ញាធរ ដោយគ្មានការត្រួតពិនិត្យ នោះឡើយ ។

កថាខណ្ឌទី ៤ នៃមាត្រា ៥ នេះ ផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរក្នុងការប្រើប្រាស់របបអាជ្ញាសឹក នៅក្នុង "កាលៈទេសៈដទៃទៀត" ដែល "សន្តិសុខជាតិប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរ" ។ ការចែងអំពី "កាលៈទេសៈដទៃទៀត" គឺមានន័យទូលាយ និងមិនច្បាស់លាស់ ដែលអាចត្រូវបានបកស្រាយយ៉ាងទូលាយ ដើម្បីឱ្យការអនុវត្តច្បាប់អាជ្ញាសឹកមានលក្ខណៈស្របច្បាប់ នៅក្នុងគ្រប់ស្ថានភាពទាំងអស់ ដែលអាជ្ញាធរយល់ថា "បង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ" ដល់សន្តិសុខជាតិ ។ ការគ្រប់គ្រងស្ថាប័នស៊ីវិលដោយយោធា គួរត្រូវបានកំណត់វិសាលភាពតូចបំផុត និងគួរត្រូវបានកំណត់ឱ្យបានច្បាស់លាស់ ចៀសវាងការអនុវត្តជ្រុលហួសហេតុ និងទាំងរំលោភបំពាន ។

មាត្រា ៦ នៃសេចក្តីព្រាងច្បាប់នេះ កំណត់អំពីមធ្យោបាយជូនដំណឹងទៅសភាជាតិក្នុងកាលៈទេសៈប្រទេសស្ថិតក្នុងភាពអាសន្ន ដោយមិនបានកំណត់អំពីយន្តការត្រួតពិនិត្យការអនុវត្តវិធានការរបស់អង្គនិតិប្រតិបត្តិនោះទេ ។ មាត្រានេះ គ្រាន់តែតម្រូវឱ្យរាជរដ្ឋាភិបាល "រាយការណ៍ជាប្រចាំ" អំពីវិធានការដែលខ្លួនបានដាក់ចេញទៅកាន់អង្គនីតិបញ្ញត្តិប៉ុណ្ណោះ ។ ក្រៅពីសិទ្ធិ "ស្នើសុំព័ត៌មានចាំបាច់បន្ថែមផ្សេងទៀត" អង្គនីតិបញ្ញត្តិពុំមានសិទ្ធិក្នុងការត្រួតពិនិត្យ ឬមិនមានយន្តការត្រួតពិនិត្យការអនុវត្តវិធានការរបស់អង្គនីតិប្រតិបត្តិនោះទេ ។ ការមិនមានយន្តការត្រួតពិនិត្យ អាចប្រហែលជាដោយសារការប្រកាសដាក់ប្រទេសជាតិក្នុងស្ថានភាពបែបនេះ ត្រូវបានធ្វើឡើងដោយការព្រមព្រៀងរួមរវាងព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា ។ ជាការសន្មត់ ប្រសិនបើម្នាក់ ក្នុងចំណោមឧត្តមមន្ត្រី និងព្រះមហាក្សត្រ មិនយល់ស្រប នោះការប្រកាសដាក់ប្រទេសស្ថិតក្នុងភាពអាសន្ន នឹងមិនកើតមានឡើងឡើយ ដោយយោងតាមមាត្រា ៣ នៃសេចក្តីព្រាងច្បាប់នេះ និងមាត្រា ២២ នៃរដ្ឋធម្មនុញ្ញ ។ ប៉ុន្តែដោយសារមាត្រា ១១ នៃរដ្ឋធម្មនុញ្ញ អនុញ្ញាតឱ្យប្រធានព្រឹទ្ធសភាអនុវត្តភារកិច្ចជំនួសអង្គព្រះមហាក្សត្រ នៅពេលព្រះអង្គប្រឈួន នោះការមិនយល់ព្រម អាចកើតមានឡើងក្នុងចំណោមនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា ។ ប៉ុន្តែស្ថានភាពនេះ អាចនឹងមិនកើតមានឡើងក្នុងស្ថានភាពប្រទេសកម្ពុជាបច្ចុប្បន្ននោះទេ ។

## ជំពូកទី ៤៖ ទោសប្បញ្ញត្តិ

មាត្រា ៧ និងមាត្រា ៨ នៃសេចក្តីព្រាងច្បាប់នេះ បានចែងយ៉ាងទូលំទូលាយ និងស្រពិចស្រពិលអំពីនិយមន័យនៃអំពើល្មើស និងទោសទណ្ឌ ដែលនេះគឺជាការរំលោភបំពានទៅលើច្បាប់អន្តរជាតិ ។ កម្រិតទោសព្រហ្មទណ្ឌទៅលើអំពើល្មើសដែលត្រូវបានកំណត់យ៉ាងស្រពិចស្រពិល ដូចជា អំពើដោយចេតនារារាំង ឬបង្កឧបសគ្គ ឬ មិនគោរព "វិធានការដាក់ចេញដោយរាជរដ្ឋាភិបាល" គឺមានលក្ខណៈធ្ងន់ធ្ងរខ្លាំង ។ ការ "មិនគោរព" អាចត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ដោយរួមទាំងអំពើសំដែងចេញតាមរយៈកាយវិការ និងតាមរយៈការចែករំលែកនូវទស្សនៈរិះគន់នៅក្នុងការសន្ទនាឯកជន ។ ការផ្តន្ទាទោសដាក់ពន្ធនាគារអតិបរមា ១០ ឆ្នាំ អាចត្រូវបានដាក់លើប្រជាពលរដ្ឋណា ដែលបានធ្វើសកម្មភាព ដែលអាជ្ញាធរអះអាងថា "បង្កឱ្យមានភាពវឹកវរ ឬប៉ះពាល់ដល់សន្តិសុខជាតិ" ។

មាត្រា ៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ បានកំណត់នូវសិទ្ធិមនុស្សជាក់លាក់មួយចំនួន ដែលរដ្ឋជាសមាជិក មិនអាចធ្វើបដិបញ្ញត្តិបានឡើយ នៅក្នុងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ជា

ពិសេសសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[16] ។ មាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិនេះ បានធានាថាមិនមានពលរដ្ឋណាម្នាក់ មានកំហុសអំពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានប្រព្រឹត្តិអំពើណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ និងអន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តិនោះឡើយ ។ អំពើដែលជាបទល្មើស ត្រូវតែកំណត់ឱ្យបានច្បាស់លាស់ ហើយផលវិបាកនៃការប្រព្រឹត្តិអំពើនោះ គួរតែត្រូវបានកំណត់ឱ្យបានដឹងនៅក្នុងច្បាប់ ។ ការមិនសន្មត់ទុកជាមុននៃអំពើល្មើស ធ្វើឱ្យមិនអាចកំណត់ទុកជាមុនថាមានអំពើល្មើសនោះកើតឡើងនៅក្នុងពេលខាងមុខ ដែលផ្ទុយនឹងកាតព្វកិច្ចរបស់កម្ពុជាក្នុងការគោរពនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ។

មាត្រា ៩ នៃសេចក្តីព្រាងច្បាប់ កំណត់អំពីទោសទណ្ឌលើនិតិបុគ្គល ដែលរួមទាំងអង្គការមិនមែនរដ្ឋាភិបាល និងសមាគម ។ យោងតាមមាត្រានេះ គ្រប់ស្ថាប័នឯកជន រួមមានអង្គការ សមាគម សហជីព ឬក្រុមមនុស្សដទៃទៀត ដែលមានលក្ខណៈសម្បត្តិជានីតិបុគ្គល អាចត្រូវបានរំលាយ ប្រសិនបើសមាជិកណាម្នាក់ ឬច្រើន ត្រូវបានរកឃើញថាមានពិរុទ្ធ ដោយសាររំលោភលើវិធានការដាក់ចេញដោយរាជរដ្ឋាភិបាល អំឡុងពេលដាក់ប្រទេសស្ថិតក្នុងភាពអាសន្ន ។ យោងតាមមាត្រា ៤២ នៃក្រមព្រហ្មទណ្ឌកម្ពុជា នីតិបុគ្គលអាចត្រូវ "ទទួលខុសត្រូវព្រហ្មទណ្ឌ" ទៅលើអំពើល្មើសដែលត្រូវបានប្រព្រឹត្តិដោយអង្គការ ឬអ្នកតំណាងរបស់ស្ថាប័នដែលជារូបវន្តបុគ្គល ។ ដូចនេះ ស្ថាប័ននោះអាចនឹងត្រូវបានផ្តន្ទាទោសចំនួនពីរ ដោយយោងតាមមាត្រា ៧ និង៨ នៃសេចក្តីព្រាងច្បាប់នេះ និងមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ។

មាត្រាខាងលើនេះ បង្កើតជាយន្តការទទួលខុសត្រូវជំនួសយ៉ាងតឹងតែង ដោយអនុញ្ញាតឱ្យអាជ្ញាធរ បិទ ឬរំលាយចោលអង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ឬសហជីព ចំពោះបទល្មើសព្រហ្មទណ្ឌដែលបានប្រព្រឹត្តិដោយសមាជិកណាម្នាក់នៃស្ថាប័ននោះ ។ យោងតាមមាត្រា ៨ នៃសេចក្តីព្រាងច្បាប់នេះ ការ "មិនគោរព" វិធានការរបស់រាជរដ្ឋាភិបាល ក៏អាចឱ្យអាជ្ញាធរបិទ ឬរំលាយចោលនូវស្ថាប័ន ឬអង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ឬសហជីពបានដែរ ។ ប្រសិនបើច្បាប់នេះ ត្រូវបានអនុវត្តនៅក្នុងពេលប្រទេសស្ថិតក្នុងភាពអាសន្ន សកម្មជនសិទ្ធិមនុស្ស និងអ្នករិះគន់អាជ្ញាធរ អាចនឹងត្រូវរលាយបាត់ទាំងស្រុង ។

## ជំពូកទី ៥៖ អវសានបញ្ញត្តិ

សេចក្តីព្រាងច្បាប់នេះ ត្រូវបានព្រាងឡើងដោយមានវិសាលភាព និងការអនុវត្តទូលំទូលាយហួសហេតុ ។ យោងតាមមាត្រា ១០ នៃសេចក្តីព្រាងច្បាប់នេះ ច្បាប់ជាតិ និងអន្តរជាតិមួយចំនួន ដែលធានានូវសិទ្ធិមនុស្សជាមូលដ្ឋាន អាចនឹងត្រូវបាននិរាករណ៍ ប្រសិនបើសេចក្តីព្រាងច្បាប់ ត្រូវបានអនុម័តដោយសភាទាំងពីរ ដោយមិនមានការកែប្រែ ។ រាជរដ្ឋាភិបាល គួរកំណត់ឱ្យបានច្បាស់លាស់ ថាតើច្បាប់ជាតិ និងកាតព្វកិច្ចរបស់អាជ្ញាធរក្រោមច្បាប់អន្តរជាតិណាខ្លះ ត្រូវបាននិរាករណ៍ ឬលុបចោល នៅពេលប្រទេសស្ថិតក្នុងភាពអាសន្ន ។ ការកំណត់ឱ្យបានច្បាស់លាស់ គួរត្រូវបានធ្វើឡើងទាំងសម្រាប់ពលរដ្ឋក្នុងការយល់ដឹង និងអនុវត្តតាម និងសម្រាប់អាជ្ញាធរនានា ដែលទទួលភារកិច្ចក្នុងការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល ៕

[16] មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ